# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ


**អគ្គិសនីកម្ពុជា**

លេខ: ៩៥៩១ អជលៈអក·២អ៨


ថ្ងៃ អង្គារ ០៤ កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ២០២០

# សេចក្តីជូនដំណឹង

**អគ្គិសនីកម្ពុជា** មានកិត្តិយសសូមជម្រាបជូនសាធារណជនឲ្យបានជ្រាបថា៖ ក្រោមការយកចិត្តទុកដាក់ខ្ពស់ក្នុងការលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋនៅតំបន់ជនបទ **រាជរដ្ឋាភិបាលកម្ពុជា** ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវ "ផែនការយុទ្ធសាស្ត្របន្ថយអត្រាថ្លៃលក់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងផ្តល់ថវិកាប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនីសម្រាប់ការបន្ថយអត្រាថ្លៃលក់នេះ"។ អនុវត្តន៍តាមផែនការនេះ នាយកដ្ឋានមូលនិធិអគ្គិសនីការូបនីយកម្មជនបទនៃអគ្គិសនីកម្ពុជា (ហៅកាត់ថា "ម.អ.ជ.") ទទួលបន្ទុកទូទាត់ប៉ះប៉ូវថ្លៃលក់អគ្គិសនីរបស់សេវាករអគ្គិសនី បង្គ្រប់ជូនគ្រួសារជនបទក្រីក្រដែលប្រើប្រាស់អគ្គិសនីតាមផ្ទះ និងប្រើប្រាស់អគ្គិសនីសម្រាប់ការបូមទឹកធ្វើកសិកម្មពីម៉ោង ៩:០០យប់ ដល់ម៉ោង ៧:០០ព្រឹក ជូនអ្នកផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ។

ដើម្បីឲ្យការអនុវត្តផែនការយុទ្ធសាស្ត្រនេះ អនុវត្តន៍ប្រកបដោយតម្លាភាព និងពុំមានការរើសអើង ម.អ.ជ. សូមស្នើសេវាករអគ្គិសនីកំពុងផ្តល់សេវាកម្មអគ្គិសនីនៅតំបន់ជនបទ មេត្តាសហការដោយឈរលើស្មារតីទទួលខុសត្រូវខ្ពស់ និងផ្តល់ទិន្នន័យពីបរិមាណអគ្គិសនីដែលគ្រួសារជនបទបានប្រើប្រាស់តាមផ្ទះ និងប្រើប្រាស់សម្រាប់ការបូមទឹកធ្វើកសិកម្មនៅតំបន់ជនបទឲ្យបានសុក្រឹត និងត្រឹមត្រូវ រួមទាំងឯកសារពាក់ព័ន្ធជូនមក ម.អ.ជ. ដើម្បីពិនិត្យ និងទូទាត់ថ្លៃប្រើប្រាស់អគ្គិសនីបំពេញបន្ថែមជូនសេវាករអគ្គិសនីជំនួសគ្រួសារជនបទដែលបានប្រើប្រាស់អគ្គិសនី ក្រោមផែនការយុទ្ធសាស្ត្រនេះ ទាន់ពេលវេលា។

ផែនការយុទ្ធសាស្ត្រនេះ ជាកម្មវិធីអនុវត្តបន្តពីឆ្នាំ២០១៦ និងនៅបន្តអនុវត្តក្នុងឆ្នាំ២០២១។

ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកលោក ជុំ ចាន់តារា ទូរស័ព្ទលេខ 015 776-770 / 011 244-246 ឬលោក ថាច់ កៀងមុនី ទូរស័ព្ទលេខ 016 988-685 ឬទាក់ទងមក ម.អ.ជ. តាមទូរស័ព្ទលេខ 089 776-770 / 023 997-600 ឬទូរសារលេខ 023 997-601 ឬអញ្ជើញមកទំនាក់ទំនងនៅនាយកដ្ឋាន ម.អ.ជ. មានទីតាំងនៅអាគារលេខ២០៥ ផ្លូវជាតិលេខ៥ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**អគ្គនាយកអគ្គិសនីកម្ពុជា**

**កែវ រតនៈ**

<u>ចម្លងជូន៖</u>

- អាជ្ញាធរអគ្គិសនីកម្ពុជា
- អគ្គនាយករងអគ្គិសនីកម្ពុជា
  ដើម្បី "ជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គិសនីកម្ពុជា**

លេខ: ៩៥៩៧ សដ៣.អក.មអជ

ថ្ងៃ អង្គារ ០៨ កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ២០២០

# សេចក្ដីជូនដំណឹង

**អគ្គិសនីកម្ពុជា** មានកិត្តិយសសូមជម្រាបជូនសាធារណជនឲ្យបានជ្រាបថា៖ គោលនយោបាយវិស័យថាមពលរបស់រាជរដ្ឋាភិបាលកម្ពុជា អាណត្តិទី៦ នៃរដ្ឋសភានេះ **រាជរដ្ឋាភិបាលកម្ពុជា** មានមហិច្ឆតាគ្រប់គ្រង និងជំរុញការអភិវឌ្ឍវិស័យថាមពលអគ្គិសនីដើម្បី "ឈានទៅសម្រេចឲ្យបានការផ្គត់ផ្គង់ថាមពលអគ្គិសនីមួយគ្រប់គ្រាន់ មានចីរភាព អាចទុកចិត្តបាន មានគុណភាព និងមានថ្លៃសមរម្យសម្រាប់អ្នកប្រើប្រាស់គ្រប់ប្រភេទ នៅគ្រប់ទីកន្លែង ទូទាំងព្រះរាជាណាចក្រកម្ពុជា"។ **អគ្គិសនីកម្ពុជា** បន្តផ្តល់ថវិកាជាអំណោយដល់នាយកដ្ឋានមូលនិធិអគ្គិសនីការូបនីយកម្មជនបទនៃអគ្គិសនីកម្ពុជា (ហៅកាត់ថា "ម.អ.ជ.") ដើម្បីបន្តអនុវត្ត "**កម្មវិធីសម្រាប់ផ្តល់ការផ្គត់ផ្គង់អគ្គិសនី ដើម្បីបូមទឹកធ្វើកសិកម្ម**"។ កម្មវិធីនេះ ជាកម្មវិធីអនុវត្តពីឆ្នាំ២០១៦ និងបន្តអនុវត្តក្នុងឆ្នាំ២០២១។ គោលបំណងនៃកម្មវិធីនេះ គឺជួយឲ្យមានការផ្គត់ផ្គង់អគ្គិសនីពីប្រព័ន្ធបណ្តាញជាតិផ្ទាល់ សម្រាប់ប្រើប្រាស់បូមទឹកធ្វើកសិកម្មនៅតម្លៃអនុគ្រោះត្រឹមតែ ៤៨០រៀលក្នុង១គីឡូវ៉ាត់ម៉ោង នៅពេលយប់ពីម៉ោង ៩:០០យប់ ដល់ម៉ោង ៧:០០ព្រឹក និងនៅតម្លៃធម្មតានៅពេលថ្ងៃពីម៉ោង ៧:០០ព្រឹក ដល់ម៉ោង ៩:០០យប់។ ជំនួយដែល ម.អ.ជ. អាចផ្តល់ឲ្យរួមមានការសាងសង់ហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី នាឡិកាស្ទង់កត់ត្រាលេខអំណានតាមពេលនិងបង់ប្រាក់មុន (នាឡិកាស្ទង់ TOU) ឬនាឡិកាស្ទង់កត់ត្រាលេខអំណានតាមពេលដែលបានកំណត់ (នាឡិកាស្ទង់ EDMI) កាតបង់ប្រាក់មុនពុំទាន់បញ្ចូលទឹកប្រាក់ ម៉ាស៊ីនបញ្ចូលទឹកប្រាក់ឡើងវិញឲ្យកាតបង់ប្រាក់មុន។ ម.អ.ជ. នឹងសាងសង់ហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីដែលចាំបាច់ (ខ្សែបណ្តាញតង់ស្យុងមធ្យម ត្រង់ស្វូម៉ាទ័រ ខ្សែបណ្តាញតង់ស្យុងទាប និងឧបករណ៍ដំណើរការអេចិន្ត្រៃយ៍ដទៃទៀត) តាមរយៈក្រុមហ៊ុនសាងសង់ដែលជ្រើសរើសដោយ ម.អ.ជ. និងផ្ទេរហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី និងប្រព័ន្ធនាឡិកាស្ទង់។ល។ ឲ្យទៅអ្នកផ្គត់ផ្គង់អគ្គិសនី ដើម្បីប្រើប្រាស់។

ដើម្បីឲ្យការអនុវត្តកម្មវិធីនេះ ដំណើរការទៅប្រកបដោយតម្លាភាព និងពុំមានការរើសអើង ម.អ.ជ. សូមស្នើសេវាករអគ្គិសនី ក្រសួងស្ថាប័នពាក់ព័ន្ធ និងអ្នកប្រើប្រាស់អគ្គិសនី មេត្តាសហការដោយឈរលើស្មារតីទទួលខុសត្រូវខ្ពស់ និងផ្តល់ព័ត៌មានស្តីពីការស្នើសុំអនុវត្តន៍កម្មវិធីនេះមក ម.អ.ជ.។

ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកលោក ជុំ ចាន់តារា ទូរស័ព្ទលេខ 015 776-770 / 011 244-246 ឬលោក ថាច់ កៀងមុនី ទូរស័ព្ទលេខ 016 988-685 ឬទាក់ទងមក ម.អ.ជ. តាមទូរស័ព្ទលេខ 089 776-770 / 023 997-600 ឬទូរសារលេខ 023 997-601 ឬអញ្ជើញមកទំនាក់ទំនងនៅនាយកដ្ឋាន ម.អ.ជ. មានទីតាំងនៅអាគារលេខ២០៥ ផ្លូវជាតិលេខ៥ សង្កាត់គីឡូម៉ែត្រលេខ៦ ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**អគ្គនាយកអគ្គិសនីកម្ពុជា**

**កែវ រតនៈ**

<u>ចម្លងជូន៖</u>
- អាជ្ញាធរអគ្គិសនីកម្ពុជា
- អគ្គនាយករងអគ្គិសនីកម្ពុជា
  ដើម្បី "ជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ